១សាំយូអែល២:១-៣៥

# ជំពូក ២

***គោលបំណង*** *បទទំនាយរបស់នាងហាណា*
*អំពើអាក្រក់របស់កូនប្រុសលោកអេលី*
*កុមារសាំយូអែលនៅក្នុងព្រះវិហារ*
*ទោសដែលកូនប្រុសអេលីត្រូវទទួល*

សេចក្តីអធិស្ឋាន និងពាក្យអរព្រះគុណដល់ព្រះ ដែលនាងហាណាបានពោល គឺជាបទទំនាយដែលទាយពីព្រះអង្គសង្គ្រោះដែលត្រូវយាងមក ប្រសូតនៅលើផែនដី។ កូនប្រុសរបស់លោកអេលីទាំងពីររូប មិនសមនឹងទទួលឋានៈជាសង្ឃបំពេញការងារក្នុងទីបរិសុទ្ធទេ។ អ្នកសំណព្វរបស់ព្រះមួយរូប បានព្រមានដល់សង្ឃអេលីថា ពូជពង្សរបស់លោកមិនបានធ្វើជាសង្ឃរបស់ព្រះជាម្ចាស់ទៀតឡើយ។ ព្រះជាម្ចាស់នឹងហៅសង្ឃមួយរូបទៀត ដើម្បីអោយមកបំពេញកិច្ចការងាររបស់ព្រះអង្គ។

## បទទំនាយរបស់នាងហាណា

ខគម្ពីរខាងក្រោមនេះ រាប់ថាជាសេចក្ដីអធិស្ឋានដ៏មានខ្លឹមសារជាទីបំផុត។

**លំដាប់នោះ ហាណាក៏អធិស្ឋានថា ចិត្តខ្ញុំម្ចាស់រីករាយសាទរចំពោះព្រះអង្គ ស្នែងខ្ញុំម្ចាស់បានថ្កើងឡើង ដោយនូវព្រះយេហូវ៉ា មាត់ខ្ញុំម្ចាស់បានបង្រួបលើគូវិវាទរបស់ខ្ញុំម្ចាស់ ដោយព្រោះខ្ញុំម្ចាស់មានសេចក្ដីអំណរចំពោះសេចក្ដីសង្គ្រោះរបស់ទ្រង់ (១សាំយូអែល២:១)។**

ស្នែងសម្ដែងអំពីកម្លាំង ដែលអាចទប់ទល់ជាមួយនឹងខ្មាំងសត្រូវ។ ស្នែងរបស់នាងហាណា គឺជាកម្លាំងរបស់ព្រះជាម្ចាស់ ដែលផ្ដល់មកអោយនាង។ ឯកម្លាំងនោះ គឺបានមកដោយសារព្រះជាម្ចាស់ប្រទានអោយនាងមានកូនប្រុសមួយ។ ពីថ្ងៃនេះទៅគេលែងដៀលត្មិះនាងថានាងជាស្រីអារទៀតហើយ។ ការណ៍នោះ បង្ខំអោយនាងពោលថា "...ដោយព្រោះខ្ញុំម្ចាស់មានសេចក្ដីអំណរ ចំពោះសេចក្ដីសង្គ្រោះរបស់ទ្រង់"។

ទាក់ទងជាមួយសេចក្ដីសង្គ្រោះ ព្រះជាម្ចាស់ផ្ដល់សេចក្ដីសង្គ្រោះដល់អ្នកជឿជាបីកាលវេលា។ កាលវេលាទីមួយ គឺយើងបានទទួលសេចក្ដីសង្គ្រោះរួចហើយ។ បទគម្ពីរមួយសម្ដែងថា "ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នកណាដែលស្ដាប់ពាក្យខ្ញុំ ហើយជឿដល់ព្រះអង្គដែលចាត់ឱ្យខ្ញុំមក អ្នកនោះមានជីវិតដ៏នៅអស់កល្បជា

និច្ច ហើយមិនដែលត្រូវជំនុំជំរះឡើយ... ” (យ៉ូហាន ៥:២៤)។ ខគម្ពីរនេះមានន័យថា ព្រះជាម្ចាស់បានរំដោះយើងអោយរួចពីអំពើបាបទាំងឡាយ នៅក្នុងគ្រាអតីតកាលកន្លងទៅ។ ទីពីរ ព្រះជាម្ចាស់បានរំដោះយើងអោយរួចអំពីអំពើស្មោកគ្រោក ក្នុងគ្រាបច្ចុប្បន្នកាល ដែលយើងកំពុងរស់សព្វថ្ងៃ។ សព្វថ្ងៃនេះយើងកំពុងតែទទួលសេចក្ដីសង្គ្រោះពីសេចក្ដីទន់ខ្សោយ របស់រូបសាច់ ដែលយើងប្រព្រឹត្តរៀងរាល់ថ្ងៃ ទាំងកាយ វាចារ និងចិត្ត។ នាងហាណាមានសេចក្ដីរីករាយចំពោះសេចក្ដីសង្គ្រោះ ដែលនាងទទួលបានក្នុងពេលដែលនាងកំពុងរស់នៅ។ ករណីនេះ ហៅថា ជាការញែកអោយបានបរិសុទ្ធ។ ទីបី សេចក្ដីសង្គ្រោះដែលកើតមាននៅក្នុងគ្រាអនាគត។ គម្ពីរ១យ៉ូហាន៣:២ បញ្ជាក់អំពីគោលទ្និនេះថា “ពួកស្ងួនភ្ងាអើយ ឥឡូវនេះយើងរាល់គ្នាជាកូនព្រះហើយ តែដែលយើងរាល់គ្នានឹងបានទៅជាយ៉ាងណាទៀត នោះមិនទាន់សំដែងមកនៅឡើយ ប៉ុន្តែយើងដឹងថា កាលណាទ្រង់លេចមក នោះយើងនឹងបានដូចជាទ្រង់ ដ្បិតដែលទ្រង់យ៉ាងណា នោះយើងនឹងឃើញទ្រង់យ៉ាងនោះឯង”។ ពេលដែលយើងទទួលបានសេចក្ដីសង្គ្រោះពីព្រះអម្ចាស់យេស៊ូវ យើងទទួលបានក្ដីសង្គ្រោះក្នុងគ្រាអតីតកាលក្នុងពេលបច្ចុប្បន្ន និងក្នុងគ្រាអនាគត។

**គ្មានព្រះណាបរិសុទ្ធ ដូចព្រះយេហូវ៉ាឡើយ ដ្បិតក្រៅពីទ្រង់គ្មានព្រះឯណាទៀតសោះ ក៏គ្មានព្រះឯណាដែលទុកជាថ្មដា ឲ្យដូចព្រះនៃយើងខ្ញុំដែរ (១សាំយូអែល២:២)។**

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ គេហៅព្រះអម្ចាស់យេហូវ៉ាថាជាថ្មដា។ នៅក្នុងគម្ពីរសញ្ញាថ្មី គេហៅព្រះអង្គថាជាថ្មជ្រុងឯក (១ពេត្រុស២:៦)។ ក្នុងគម្ពីរម៉ាថាយ១៦:១៨ ព្រះអម្ចាស់យេស៊ូវមានបន្ទូលពីទ្រង់ថា "នៅលើថ្មនេះ ខ្ញុំសង់ពួកជំនុំខ្ញុំ"។ នាងហាណាជឿលើព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដែលទ្រង់ជាថ្មដាដ៏រឹងមាំ។

> **កុំឱ្យពោលពាក្យអំនួតដ៏លើសលប់ដូច្នេះទៀត កុំឱ្យមានសេចក្តីឃ្មើសឃ្មងចេញពីមាត់ឯងឡើយ ពីព្រោះព្រះយេហូវ៉ាទ្រង់ជាព្រះដែលជ្រាបទាំងអស់ គឺទ្រង់ហើយ ដែលថ្លឹងអស់ទាំងអំពើ (១សាំយូអែល២:៣)។**

នៅពេលដែលយើងធ្វើការអធិស្ឋាន សូមយើងធ្វើការប្រយ័ត្នខ្លួនផង ក្រែងលោយើងមានចិត្តអួតអាងណាមួយ ដែលញ៉ាំងអោយយើងដួលនៅចំពោះព្រះអង្គ។ យើងត្រូវទទួលស្គាល់សេចក្តីទន់ខ្សោយ ភាពមិនគ្រប់លក្ខណ៍ និងភាពអសមត្ថភាពរបស់យើង។ ប៉ុន្តែ បើលោកអ្នកមានព្រះអម្ចាស់យេស៊ូវជាអង្គសង្គ្រោះ លោកអ្នកអាចហៅព្រះវរបិតាថាជាឪពុករបស់យើងបាន។ ក្នុងនាមយើងជាកូនរបស់ព្រះអង្គ យើងមានសិទ្ធិអធិស្ឋានទូលសូមដល់ព្រះអង្គក្នុងនាមព្រះយេស៊ូវគ្រីស្ទ។ បើលោកអ្នកមិនស្គាល់ព្រះអម្ចាស់យេស៊ូវជាអង្គសង្គ្រោះទេ លោកអ្នកមិនមានសិទ្ធិហៅព្រះថាជាព្រះវរបិតាព្រមទាំងបន្ទោសទ្រង់ ដោយសារទ្រង់មិនឆ្លើយនឹងសេចក្តីអធិស្ឋានរបស់លោកអ្នក

នោះឡើយ។

**[៤]ធ្នូនៃពួកខ្លាំងពូកែបានបាក់ហើយ តែពួកអ្នកដែលល្វើយ បានក្រវាត់ឡើងដោយកំឡាំងវិញ [៥]ពួកអ្នកដែលពីដើមឆ្អែត គេបានទៅជាស៊ីឈ្នួលចិញ្ចឹមជីវិត តែពួកអ្នកដែលពីដើមអត់ឃ្លានគេបានឆ្អែតវិញ បានជានាងស្រីអារបង្កើតកូនបាន៧ ហើយនាងដែលមានកូនច្រើនបានរីងរៃទៅ [៦]ឯសេចក្តីស្លាប់ ហើយនឹងជីវិត នោះស្រេចនៅព្រះយេហូវ៉ា ទ្រង់នាំចុះទៅដល់ស្ថានឃុំព្រលឹងមនុស្សស្លាប់ ហើយក៏នាំឡើងមកវិញដែរ (១សាំយូអែល២:៤-៦)។**

អត្ថបទខាងលើសម្តែងបញ្ជាក់ថា ព្រះជាម្ចាស់ជាអង្គតែមួយគត់ដែលប្រទានជីវិតដល់សត្វលោកគ្រប់ប្រភេទ។ លោកយ៉ូបអះអាងថា "...ទូលបង្គំបានចេញពីផ្ទៃម្តាយមកដោយខ្លួនទទេ ហើយនឹងត្រឡប់ទៅវិញ ដោយទទេដែរ ព្រះយេហូវ៉ាទ្រង់បានប្រទានមក ហើយទ្រង់ក៏បានដកយកទៅវិញ សូមឱ្យព្រះនាមព្រះយេហូវ៉ាបានព្រះពរចុះ" (យ៉ូប១:២១)។ ព្រះជាម្ចាស់ទ្រង់ប្រទានជីវិតដល់ភាវៈគ្រប់ប្រភេទ។ ព្រះអង្គក៏មានសិទ្ធិអាចដកយកជីវិតទៅវិញ តាមតែទ្រង់សព្វព្រះហឫទ័យ។ ព្រះជាម្ចាស់មានអំណាចគ្រប់គ្រាន់។ បើព្រះជាម្ចាស់ដកជីវិតពីនរណាម្នាក់ តើមាននរណាបន្ទោសព្រះអង្គបានឬទេ? ព្រះអង្គមិនចាំបាច់សូមទោសដល់មនុស្សណាឡើយ ព្រោះព្រះអង្គមាន

តែងជំនុំជំរះដល់មនុស្សអាក្រក់។

> **ឯការក្រហើយនឹងមាន នោះស្រេចនៅព្រះយេហូវ៉ា គឺទ្រង់ដែលបន្ទាបទៅ ហើយគឺទ្រង់ដែលលើកឡើងដែរ (១សាំយូអែល ២:៧)។**

កន្លងមកសូម្បីអ្នកបរិសុទ្ធរបស់ព្រះ ក៏ចេះសួរថា "ហេតុអ្វីបានជាមនុស្សខ្លះមាន ហើយមនុស្សខ្លះក្រ?" ខ្ញុំផ្ទាល់មិនដឹងថាហេតុអ្វី បានជាព្រះអម្ចាស់អោយមនុស្សខ្លះធ្វើជាអ្នកមាន ហើយមនុស្សខ្លះទៅជាអ្នកក្រឡើយ។ ខ្ញុំមិនចាំបាច់ចង់ដឹងធ្វើអ្វីទេអំពីដំណើរនេះ។ ខ្ញុំនឹងសួរដល់ព្រះនៅថ្ងៃដែលខ្ញុំទៅជួបទ្រង់។ នៅថ្ងៃនោះ ទ្រង់ពិតជាមានចម្លើយសម្រាប់ខ្ញុំ។

> **៨ ទ្រង់លើកមនុស្សក្រីក្រពីធូលីដី ហើយស្រង់មនុស្សកំសត់ទុរគតពីគំនរលាមកឡើង ឱ្យគេបានអង្គុយជាមួយនឹងពួកត្រកូលខ្ពស់ ហើយឱ្យគេគ្រងមរដកជាបល្ល័ង្កឧត្តុង្គឧត្តម ដ្បិតអស់ទាំងសសរនៃផែនដីជារបស់ផងព្រះយេហូវ៉ា ហើយទ្រង់បានដាក់លោកីយនៅលើសសរទាំងនោះ ៩ ទ្រង់នឹងគាំពារជើងនៃពួកអ្នកបរិសុទ្ធរបស់ទ្រង់ តែពួកអាក្រក់នឹងត្រូវស្ងៀមស្ងាត់នៅក្នុងទីងងឹតវិញ ដ្បិត**

**មនុស្សមិនមែនឈ្នះដោយនូវកំឡាំងបានទេ (១សាំយូអែល២: ៨-៩)។**

បើតាមប្រាជ្ញារបស់មនុស្ស មនុស្សមិនអាចជួយធ្វើអ្វីដល់ព្រះបានទេ។ គ្រីស្ទបរិស័ទត្រូវទទួលស្គាល់ហេតុការណ៍នេះអោយច្បាស់។ បើលោកអ្នកបម្រើព្រះអង្គដោយមានព្រះវិញ្ញាណបរិសុទ្ធជួយដល់ជីវិតលោកអ្នក លោកអ្នកពិតជាបានសម្រេចមែន។ យើងត្រូវរៀនពឹងពាក់នៅលើព្រះអង្គ ព្រមទាំងសម្រាកកម្លាំងនៅលើព្រះអង្គរៀងរាល់ពេលវេលា។

**ឯពួកអ្នកដែលតតាំងនឹងព្រះយេហូវ៉ា នោះនឹងត្រូវខ្ទេចខ្ទីទៅ ទ្រង់នឹងបញ្ចេញផ្គរលាន់ពីលើមេឃមកទាស់នឹងគេ ព្រះយេហូវ៉ាទ្រង់នឹងជំនុំជំរះ រហូតដល់អស់ទាំងចុងផែនដី ហើយទ្រង់នឹងប្រទានអំណាចដល់ស្តេចនៃទ្រង់ ព្រមទាំងដំកើងស្នែងនៃអ្នកដែលទ្រង់បានចាក់ប្រេងតាំងឡើងផង (១សាំយូអែល២:១០)។**

ខខាងលើសម្តែងអំពីព្រះគ្រីស្ទ ដែលជាអង្គសង្គ្រោះ។ នៅក្នុងភាសាហេព្រើរពាក្យថា "ព្រះគ្រីស្ទ" មានន័យថា ចាក់ប្រេងតាំង។ នៅក្នុងភាសាក្រេកហៅថា គ្រីស្ទូ។ នៅក្នុងព្រះគម្ពីរសញ្ញាថ្មីយើងហៅព្រះនាមទ្រង់ថា ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ "ព្រះ

គ្រីស្ទ” មានន័យថា អង្គដែលព្រះជាម្ចាស់ចាក់ប្រេងតាំងអោយយាងមកទទួលអំពើបាប ជំនួសមនុស្សលោក។

**រួចពីនោះហើយ អែលកាណាក៏ត្រឡប់វិលទៅឯផ្ទះនៅរ៉ាម៉ាវិញ តែឯកូនតូចបាននៅធ្វើការងារថ្វាយព្រះយេហូវ៉ា នៅចំពោះអេលីដ៏ជាសង្ឃ (១សាំយូអែល២:១១)។**

នាងហាណាយកកូនរបស់នាងឈ្មោះសាំយូអែល ទៅផ្ញើនៅក្នុងរោងឧបោសថ។ រោងឧបោសថ គួរតែជាកន្លែងបរិសុទ្ធ។ ប៉ុន្តែ នៅក្រោមសង្ឃអេលី រោងឧបោសថរបស់ព្រះ មិនមែនជាកន្លែងដែលគួរអោយមនុស្សទៅថ្វាយបង្គំព្រះអង្គនៅទីនោះទេ។

## អំពើអាក្រក់របស់កូនប្រុសលោកអេលី

**រីឯពួកសង្ឃ ជាកូនរបស់អេលី គេជាមនុស្សតិរច្ឆានអាក្រក់ ឥតស្គាល់ដល់ព្រះយេហូវ៉ាទេ (១សាំយូអែល២:១២)។**

កូនប្រុសទាំងពីររូបរបស់លោកអេលី គឺជាកូនរបស់សាតាំង។ បុរសទាំងពីរ

រូបនេះ មិនបានទទួលសេចក្ដីសង្គ្រោះពីព្រះជាម្ចាស់ទេ។ ទោះបីអ្នកទាំងពីរនេះមិនបានទទួលសេចក្ដីសង្គ្រោះពីព្រះជាម្ចាស់យ៉ាងណាក៏ដោយ ក៏គេមានសិទ្ធិបម្រើដល់ព្រះនៅក្នុងរោងឧបោសថដែរ។

យើងជាគ្រីស្ទបរិស័ទ ជួនកាលមានការកក់ក្ដៅខ្លាំងពេកដោយទុកកូនរបស់យើងអោយរៀនជាមួយនឹងសាលាគ្រីស្ទបរិស័ទ។ ខ្ញុំសូមអោយលោកអ្នកកុំអោយយល់ច្រឡំពីពាក្យដែលខ្ញុំនិយាយនេះ។ សាលាគ្រីស្ទបរិស័ទមានបរិយាកាសខាងព្រលឹងវិញ្ញាណល្អណាស់។ ប៉ុន្តែ បញ្ហាដែលយើងមាន គឺកាលណាយើងមានការកក់ក្ដៅនឹងផ្ញើកូនរបស់យើងជាមួយនឹងសាលាគ្រីស្ទបរិស័ទហើយ យើងមិនបានអធិស្ឋានអោយកូនយើងឡើយ។ នៅពេលយើងមិនអធិស្ឋានអោយកូនយើង កូនយើងក៏ធ្លាក់ខ្លួនទៅក្នុងផែនការអាក្រក់របស់សាតាំង។ តើសាតាំងអាស្រ័យនៅទីណា? នៅក្នុងព្រះគម្ពីរសញ្ញាថ្មី សាតាំងអាស្រ័យនៅបន្ទប់ខាងលើ គឺជាកន្លែងដែលព្រះអម្ចាស់យេស៊ូវគ្រីស្ទ សោយអាហារចុងក្រោយបង្អស់ជាមួយនឹងសិស្សរបស់ទ្រង់។ បន្ទប់ណាដែលយើងយល់ថា ជាបន្ទប់កាន់សាសនាក្រាស់ក្រែល ជាបន្ទប់ដែលអាចមានគ្រោះថ្នាក់ខ្លាំងណាស់ដែរ។ សូមយើងកុំទុកចិត្តនៅលើបន្ទប់ ឬទីកន្លែង តែសូមទុកចិត្តនៅលើព្រះជាម្ចាស់និងវត្តមានរបស់ទ្រង់ដែលគង់នៅទីកន្លែងនោះវិញ។

កុមារាសាំយូអែលស្ថិតនៅក្នុងទីកន្លែងដែលមានគ្រោះថ្នាក់ជាទីបំផុត។ ប៉ុន្តែម្ដាយរបស់កុមារាសាំយូអែល ចេះតែអធិស្ឋានអោយកូន ដើម្បីអោយអាចនឹងមានគំនិតប្រាជ្ញាវាងវៃកោតខ្លាចដល់ព្រះជាម្ចាស់។

**១៣ឯទំលាប់ដែលគេប្រព្រឹត្តចំពោះបណ្តាជន នោះគឺដូច្នេះ បើ
មានអ្នកណាថ្វាយយញ្ញបូជា នោះអ្នកបំរើរបស់សង្ឃតែងយកសម
មានធ្មេញ៣ មកកាន់នៅដៃ ក្នុងពេលដែលគេកំពុងស្ងោរសាច់
១៤ហើយចាក់ចុះទៅក្នុងខ្ទះ ឬថ្ងាង ឬឆ្នាំង រួចសង្ឃក៏យកសាច់
ទាំងអស់ដែលជាប់នឹងសមនោះមក គេធ្វើដូច្នោះដល់ពួកអ៊ីស្រា
អែលទាំងប៉ុន្មាន ដែលមកឯស៊ីឡូរ ១៥មួយទៀតមុនដែល
គេដុតខ្លាញ់ នោះអ្នកបំរើរបស់ពួកសង្ឃ ក៏មកនិយាយនឹងមនុស្ស
ដែលថ្វាយយញ្ញបូជាថា ចូរឱ្យសាច់ដែលសំរាប់អាំងដល់ពួកសង្ឃ
មក ដ្បិតលោកមិនយកសាច់ស្ងោរពីឯងទេ លោកយកតែសាច់
ឆៅវិញ ១៦បើសិនជាអ្នកនោះឆ្លើយឃាត់ថា ចាំឱ្យដុតខ្លាញ់មុន
សិន រួចសឹមយកតាមចិត្តចុះ នោះគេឆ្លើយឡើងថា ទេ ត្រូវតែឱ្យ
មកឥឡូវនេះ បើមិនដូច្នោះ អញនឹងយកទាំងបង្ខំ (១សាំយូអែល
២:១៣-១៦)។**

កូនប្រុសទាំងពីររូបរបស់សង្ឃអេលី ធ្វើជាសង្ឃដែរ ប៉ុន្តែគឺជាសង្ឃដាច់សីល។ ពួកសង្ឃឥតសីល កំពុងគ្រប់គ្រងរោងឧបោសថរបស់ព្រះជាមាស់។ តើគួរដែរឬទេ?

**ដូច្នេះបាបរបស់មនុស្សកំឡោះទាំងនោះ មានទំងន់ខ្លាំងណាស់ នៅចំពោះព្រះយេហូវ៉ា ដ្បិតគេបានមើលងាយដល់ដង្វាយនៃ ព្រះយេហូវ៉ា (១សាំយូអែល២:១៧)។**

សេចក្តីស្មោកគ្រោករបស់សង្ឃទាំងពីររូបនេះ ធ្វើអោយមនុស្សដែលចូលមកថ្វាយបង្គំនៅក្នុងរោងឧបោសថ លែងចង់ស្គាល់ព្រះជាម្ចាស់។ ពួកកូនចៅសាសន៍អ៊ីស្រាអែល បានឃើញកិរិយាប្រព្រឹត្តអាក្រក់ជូរជាតិរបស់កូនប្រុសលោកអេលីដែលជាសង្ឃ គេក៏នាំគ្នាបែរចេញពីព្រះជាម្ចាស់។ សព្វថ្ងៃនៅក្នុងក្រុមជំនុំរបស់ព្រះអង្គក៏យ៉ាងដូច្នោះដែរ បើយើងមិនព្រមប្រឈមមុខសម្អាតអំពើបាប និងអំពើស្មោកគ្រោកដែលមាននៅក្នុងក្រុមជំនុំទេ មនុស្សមិនអាចបែរមករកព្រះជាម្ចាស់ឡើយ។ សូមចាំថាមនុស្សគ្រប់រូបចេះគិតពិចារណាដឹងល្អដឹងអាក្រក់ដែរ។ បើនៅក្នុងព្រះវិហារជាកន្លែងអាក្រក់ហើយ តើគេចាំបាច់មកទីនេះធ្វើអ្វី ដ្បិតក្តីអាក្រក់មាននៅគ្រប់ទីកន្លែងនៅលើលោកនេះ។ ក្រុមជំនុំរបស់ព្រះខ្លះ ជាក្រុមជំនុំដែលប្រមូលអំពើបាបដាក់បង្គរនៅក្នុងព្រះវិហារអោយបានរឹតតែច្រើន។ ក្រុមជំនុំខ្លះ ជាក្រុមជំនុំប្រមឹក ក្រុមជំនុំខ្លះ ជាក្រុមជំនុំលេងល្បែងតុងទីន ក្រុមជំនុំខ្លះជាក្រុមជំនុំខ្ចីលុយដង្វាយយកទៅធ្វើរបររកស៊ី។ ក្រុមជំនុំរបៀបនេះ គឺជាក្រុមជំនុំដែលគ្រប់គ្រងដោយពួកសង្ឃឥតសីល។ ក្រុមជំនុំឥតសីលមានក្នុងពេលសព្វថ្ងៃនេះ ក៏ដូចជាមាននៅក្នុងសម័យកូនប្រុសលោកអេលីគ្រប់គ្រងរោង

ឧបោសថដែរ។

## កុមារសាំយូអែលនៅក្នុងព្រះវិហារ

> **[១៨]ឯសាំយូអែល ជាក្មេងតូចនោះ ក៏តែងពាក់អេផូឌធ្វើពីសំពត់ខ្លូត
> ទេស ដើម្បីសំរេចការងារនៅចំពោះព្រះយេហូវ៉ា [១៩]ហើយម្តាយ
> ក៏ធ្វើអាវតូច១ យកមកឱ្យរាល់តែឆ្នាំ ក្នុងកាលដែលនាងឡើងមក
> ជាមួយនឹងប្តី ដើម្បីថ្វាយយញ្ញបូជាដែលត្រូវថ្វាយរាល់តែឆ្នាំ
> (១សាំយូអែល២:១៨-១៩)។**

កុមារសាំយូអែលរស់នៅក្នុងក្រោមឥទ្ធិពលនៃសង្ឃឥតសីលទាំងពីររូប ដែលត្រូវជាកូនប្រុសរបស់សង្ឃអេលី។ ម្តាយរបស់កុមារសាំយូអែលមិនដែលភ្លេចលោកទេ។ រៀងរាល់ឆ្នាំនាងតែងតែដេរខោអាវ ដើម្បីយកទៅអោយកូន ពេលដែលនាងឡើងទៅថ្វាយដង្វាយដុត។

> **[២០]នោះអេលី លោកឱ្យពរដល់អែលកាណា នឹងប្រពន្ធផងថា សូម
> ព្រះយេហូវ៉ាប្រទានឱ្យអ្នកបានពូជពង្ស ដោយសារស្រីនេះ ជំនួស
> កូននេះដែលនាងបានសូមពីទ្រង់ រួចគេក៏ត្រឡប់វិលទៅផ្ទះវិញ**

**[២១] ក្រោយមក ព្រះយេហូវ៉ាទ្រង់ក៏ប្រោសប្រទានឱ្យនាងហាណាមានទំងន់ បង្កើតបានកូនប្រុស៣កូនស្រី២ទៀត ឯសាំយូអែលជាក្មេងតូចនោះ ក៏មានវ័យធំឡើងនៅចំពោះព្រះយេហូវ៉ា (១សាំយូអែល២:២០-២១)។**

ព្រះជាម្ចាស់សម្តែងសេចក្តីសប្បុរសរបស់ទ្រង់ ដល់នាងហាណា។ បន្ទាប់ពីសាំយូអែលកើតមក ព្រះអង្គប្រទានអោយនាងហាណាមានកូនប្រាំនាក់ថែមទៀត។ ប៉ុន្តែ ទោះបីនាងមានកូនប្រាំនាក់ថែមទៀតក៏ដោយ នាងមិនដែលភ្លេចសាំយូអែលដែលជាកូនបងបង្អស់ កំពុងបម្រើព្រះអង្គនៅក្នុងរោងឧបោសថទេ។ រៀងរាល់ឆ្នាំនាងតែងតែដេរខោអាវយកមកផ្ញើកូនជានិច្ច។ ទោះបីសាំយូអែលរស់នៅក្នុងបរិយាកាសអាប់អួរក្នុងរោងឧបោសថ កុមារសាំយូអែលបានធំដឹងក្តីក្នុងការស្គាល់ដល់ព្រះអម្ចាស់យេហូវ៉ាជាព្រះរបស់លោក។

## ទោសដែលកូនប្រុសសង្ឃអេលីត្រូវទទួល

**វីឯអេលី លោកចាស់ណាស់ហើយ លោកក៏បានឮពីការទាំងប៉ុន្មាន ដែលពួកកូនខ្លួនបានប្រព្រឹត្តដល់ពួកអ៊ីស្រាអែលទាំងអស់**

**ព្រមទាំងអំពើ ដែលគេតែងដេកនឹងពួកស្រីៗ ជាអ្នកធ្វើការងារនៅមាត់ទ្វារត្រសាលជំនុំផង (១សាំយូអែល២:២២)។**

សង្ឃអេលីទម្រើសកូនហួសហេតុណាស់។ លោកដឹងថាកូនលោកបានប្រព្រឹត្តអំពើលាមកនៅក្នុងរោងឧបោសថរបស់ព្រះដែរ តែលោកបានបិទភ្នែកមិនព្រមស្តីប្រដៅដល់កូនលោកអោយបានហ្មត់ចត់ឡើយ។ នៅក្នុងខខាងលើយើងឃើញថា សង្ឃទាំងពីររូប ដែលត្រូវជាកូនរបស់សង្ឃអេលី បានប្រព្រឹត្តអំពើបាបយ៉ាងធ្ងន់ធ្ងរ។ ខគម្ពីរខាងលើសម្តែងថា កូនប្រុសទាំងពីរដែលបំពេញនាទីជាសង្ឃ "...តែងដេកនឹងពួកស្រីៗ ជាអ្នកធ្វើការងារនៅមាត់ទ្វារត្រសាលជំនុំ"។ អំពើស្មោកគ្រោកនៃការកំផិតសហាយស្មន់កើតឡើងនៅក្នុងរោងឧបោសថរបស់ព្រះអម្ចាស់យេហូវ៉ា។ សព្វថ្ងៃក៏មានរឿងនេះកើតឡើងនៅចំពោះពួកសង្ឃដែរ។ មនុស្សលោកមិនដែលបានផ្លាស់ប្រែក្នុងកិរិយានេះនៅឡើយទេ។ នៅជំនាន់លោកណូអេ អំពើផិតក្បត់បានមានយ៉ាងជោរជន់នៅក្នុងរង្វង់អ្នកកាន់សាសនាដែរ។ សម័យលោកសាំយូអែល ក៏កូនប្រុសរបស់លោកអេលីទាំងពីររូបបានធ្វើបាប។ សម័យសព្វថ្ងៃក៏មានអ្នកកាន់សាសនា ប្រព្រឹត្តអំពើលាមកអាក្រក់នៅក្នុងទីបរិសុទ្ធ។

**ដូច្នេះលោកសួរថា ហេតុអ្វីបានជាឯងប្រព្រឹត្តអំពើយ៉ាងនេះ ដ្បិតអញបានឮបណ្តាជននិយាយ ពីអំពើអាក្រក់របស់ឯងនេះ**

**(១សាំយូអែល២:២៣)។**

អំពើពាលារបស់ពួកសង្ឃដែលត្រូវជាកូនរបស់សង្ឃអេលី បានឮខ្ចរខ្ចាយនៅក្នុងប្រទេសអីស្រាអែលទាំងមូល។ ប៉ុន្តែ ទោះជាយ៉ាងនោះក៏ដោយ សង្ឃអេលីគ្រាន់តែហៅកូនប្រុសរបស់លោកមក ស្តីអោយបន្តិចបន្តួច។

**កុំឡើយ កូនអើយ ដ្បិតសេចក្តីដែលអញឮគេនិយាយនោះមិនល្អទេ យ៉ាងនោះឯងនាំឲ្យរាស្ត្ររបស់ព្រះយេហូវ៉ាប្រព្រឹត្តរំលងហើយ (១សាំយូអែល២:២៤)។**

បើពួកសង្ឃប្រព្រឹត្តអំពើអាក្រក់យ៉ាងណា ពួកបរិស័ទ ក៏ធ្វើអំពើអាក្រក់យ៉ាងនោះដែរ។ កូនប្រុសទាំងពីររូបរបស់សង្ឃអេលី ដែលបំពេញតួនាទីជាសង្ឃ នាំសាសន៍អីស្រាអែលប្រព្រឹត្តអំពើបាប។ សង្ឃអេលីមិនបានស្តីប្រដៅកូនអោយបានត្រឹមត្រូវទេ គឺគ្រាន់តែហៅកូនយកមកបន្ទោសបន្តិចបន្តួចតែប៉ុណ្ណោះ។ សង្ឃអេលីទម្រើសកូនខ្លាំងណាស់។

**២៥ បើមនុស្សម្នាក់ធ្វើបាបនឹងម្នាក់ទៀត នោះមានព្រះទ្រង់ជំនុំជំរះដល់អ្នកនោះ តែបើមនុស្សធ្វើបាបនឹងព្រះយេហូវ៉ាវិញ នោះតើ**

**មានអ្នកណានឹងជួយអង្វរឱ្យអ្នកនោះបាន ប៉ុន្តែគេមិនព្រមស្តាប់**
**តាមឪពុកទេ ព្រោះព្រះយេហូវ៉ាទ្រង់សព្វព្រះហឫទ័យនឹងប្រហារ**
**ជីវិតគេចោល**
**២៦ ឯសាំយូអែល ជាក្មេងនោះ ក៏ចេះតែមានវ័យ**
**ចំរើនធំឡើង ជាទីគាប់ព្រះហឫទ័យដល់ព្រះយេហូវ៉ា ព្រមទាំង**
**គាប់ចិត្តដល់មនុស្សលោកកាន់តែច្រើនឡើងផង (១សាំយូអែល**
**២:២៥-២៦)។**

សាំយូអែលរស់នៅក្នុងព្រះវិហារ ក្រោមបរិយាកាសស្អុយគគ្រុកនៅក្នុងរោងឧបោសថ។ ប៉ុន្តែ ទោះជាយ៉ាងនោះក្តី សាំយូអែលបានធំដឹងក្តីឡើង ដោយពេញព្រះទ័យដល់ព្រះជាម្ចាស់ និងពេញចិត្តដល់មនុស្សលោក។ លោកសម្រេចចិត្តញែកខ្លួនរបស់លោករស់នៅក្នុងជីវិតបរិសុទ្ធថ្វាយដល់ព្រះជាម្ចាស់។ ម្តាយរបស់លោក គឺនាងហាណា អធិស្ឋានជូនលោកជានិច្ច។ ព្រះជាម្ចាស់ក៏បានប្រើប្រាស់លោកសាំយូអែលដូចសេចក្តីអធិស្ឋានរបស់ម្តាយលោកមែន។

**២៧ គ្រានោះ មានអ្នកសំណប់របស់ព្រះមកឯអេលីពោលថា ព្រះ**
**យេហូវ៉ាទ្រង់មានបន្ទូលយ៉ាងដូច្នេះ តើអញមិនបានលេចមក ឱ្យ**
**ពួកវង្សនៃឰយុកោឯងឃើញ ពីកាលដែលគេនៅក្នុងដំណាក់**
**ផារ៉ោន នៅស្រុកអេស៊ីព្ទទេឬអី**
**២៨ តើអញមិនបានរើសយកគេ**

**ពីពូជអំបូរសាសន៍អ៊ីស្រាអែលទាំងប៉ុន្មាន មកធ្វើជាសង្ឃដល់អញ
ឱ្យបានពាក់អេផូឌ ឡើងទៅឯអាសនាអញ ដើម្បីនឹងដុតគ្រឿង
ក្រអូបនៅមុខអញ ព្រមទាំងចែកដង្វាយទាំងប៉ុន្មានដែលពួកកូន
ចៅអ៊ីស្រាអែលដុតថ្វាយ ឱ្យដល់ពួកគ្រួពូយុកោឯងផងទេឬអី
២៩ បើដូច្នេះ ហេតុអ្វីបានជាឯងរាល់គ្នាជាន់ឈ្លីយញ្ញបូជា នឹង
ដង្វាយរបស់អញទាំងប៉ុន្មាន ដែលអញបានបង្គាប់ឱ្យថ្វាយនៅក្នុង
ដំណាក់អញ ដោយរាប់អានកូនឯងជាជាងអញវិញ ដើម្បីនឹងធ្វើ
ឱ្យខ្លួនធាត់ធំ ដោយសារចំណែកវិសេសជាងគេក្នុងអស់ទាំង
ដង្វាយនៃសាសន៍អ៊ីស្រាអែល ជារាស្ត្ររបស់អញដូច្នេះ (១សាំយូ
អែល២:២៧-២៩)។**

ព្រះជាម្ចាស់បញ្ជូនអ្នកសំណព្វរបស់ព្រះអង្គ ទៅជម្រាបដល់សង្ឃអេលីដែលលោកមានវ័យចាស់ណាស់ហើយថា ព្រះអង្គមិនរើសពូជរបស់សង្ឃអេលីអោយធ្វើជាសង្ឃទៀតទេ។ ព្រះអង្គនឹងរើសមនុស្សម្នាក់ទៀត ធ្វើជាសង្ឃផង ជាហោរាផង។ ជននោះ គឺសាំយូអែល។ លោកសាំយូអែលបង្ហាត់បង្រៀនដល់មនុស្សលោកអំពីច្បាប់របស់ព្រះជាម្ចាស់។ ឯនាទីរបស់លោក គឺជាហោរារបស់ព្រះដ៏ខ្ពស់បំផុត។

**ហេតុនោះ ព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល ទ្រង់មាន**

**បន្ទូលថា អញបានសន្យាឱ្យពួកគ្រួឯង នឹងវង្សឰយុកោឯង បាន ដើរនៅមុខអញជាដរាបទៅ តែឥឡូវនេះ ព្រះយេហូវ៉ាទ្រង់មាន បន្ទូលយ៉ាងនេះវិញថា សូមឱ្យគំនិតនោះបានឆ្ងាយចេញពីអញទៅ ដ្បិតអស់អ្នកណាដែលលើកដំកើងអញ នោះអញនឹងដំកើងអ្នក នោះឡើងដែរ ហើយអ្នកណាដែលមើលងាយដល់អញ នោះអញ ក៏មិនរាប់អានដល់គេដែរ (១សាំយូអែល២:៣០)។**

ព្រះជាម្ចាស់ទាមទារអោយយើងរស់នៅប្រចាំថ្ងៃដោយសរសើរតម្កើង ថ្វាយកិត្តិស័ព្ទដល់ព្រះជាម្ចាស់។ គម្ពីរទំនុកដំកើង១០៧:១-២សម្តែងថា "ឱសូមអរព្រះគុណដល់ព្រះយេហូវ៉ា ដ្បិតទ្រង់ល្អ សេចក្តីសប្បុរសនៃទ្រង់ស្ថិតស្ថេរនៅជានិច្ច គួរឱ្យពួកអ្នកដែលព្រះយេហូវ៉ាបានប្រោសលោះ បានថាដូច្នេះដែរ គឺអស់អ្នកដែលទ្រង់បានលោះឱ្យរួចពីកណ្តាប់ដៃនៃពួកខ្មាំងសត្រូវនោះ"។ ត្រូវអោយយើងដែលជាកូនព្រះ ចេះពោលពាក្យអរព្រះគុណដល់ព្រះយេហូវ៉ា ដ្បិតទ្រង់ល្អ។ យើងត្រូវរស់ក្នុងជីវិតដែលមានការតម្កើងដល់ព្រះជាម្ចាស់រៀងរាល់ថ្ងៃ។

**៣១ មើល នឹងមានគ្រាមកដល់ នោះអញនឹងកាត់អំណាចរបស់ឯង ចេញ ព្រមទាំងអំណាចនៃពួកវង្សឰយុកោឯងដែរ រហូតដល់គ្មាន មនុស្សចាស់នៅក្នុងជំនួរវង្សឯងឡើយ ៣២ នៅកណ្តាលគ្រប់**

**ទាំងការចំរើន ដែលព្រះទ្រង់នឹងប្រោសប្រទានដល់សាសន៍**
**អ៊ីស្រាអែល នោះឯងនឹងឃើញមានទុក្ខវេទនាកើតដល់ពួក**
**គ្រួសារឯងវិញ ហើយនឹងគ្មានមនុស្សចាស់នៅក្នុងជំនួរវង្សឯងជា**
**ដរាបទៅ ៣៣អញមិនកាត់ពួកឯងទាំងអស់ចេញពីអាសនាអញទេ**
**ចំណែកអ្នកដែលអញមិនកាត់ចេញ នោះនឹងបានសំរាប់នាំឱ្យ**
**ស្រវាំងដល់ភ្នែកឯង ហើយនឹងបញ្ឈឺចិត្តឯងវិញ ឯពូជដែល**
**ចំរើននៅក្នុងគ្រួឯង គេនឹងស្លាប់ទៅ ពីកាលកំពុងនៅពេញវ័យ**
**៣៤នេះជាទីសំគាល់ដល់ឯង ជាការដែលត្រូវកើតដល់ហុបនី នឹង**
**ភីនេហាស កូនឯងទាំង២ គឺគេនឹងស្លាប់ទៅទាំង២នាក់នៅថ្ងៃ**
**តែ១ (១សាំយូអែល២:៣១-៣៤)។**

បទទំនាយទាំងអម្បាលមាណដែលរៀបរាប់នៅក្នុងខខាងលើ បានកើតឡើងរួចទៅហើយ។ នៅពេលដែលយើងសិក្សាព្រះបន្ទូលរបស់ព្រះអង្គ ជាបន្តបន្ទាប់ យើងនឹងឃើញហេតុការណ៍ទាំងនោះជាពិតប្រាកដ។

**រួចអញនឹងបង្កើតឱ្យមានសង្ឃ១ដែលស្មោះត្រង់ដល់អញ ជាអ្នកដែលនឹងធ្វើតាមចិត្តតាមគំនិតអញវិញ ហើយអញនឹងបង្កើតឱ្យអ្នកនោះមានគ្រួដ៏រឹងប៉ឹង អ្នកនោះនឹងដើរនៅចំពោះអ្នកដែលអញ**

**ចាក់ប្រេងតាំងឱ្យ ជារៀងរាបដរាបទៅ (១សាំយូអែល២:៣៥)។**

តើខគម្ពីរខាងលើ សម្តែងអំពីអង្គណា? ខគម្ពីរខាងលើនេះ សម្តែងអំពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ សេចក្តីអធិស្ឋានរបស់នាងហាណាសម្តែងអំពីព្រះចមក្សត្រា ដែលហៅថា ព្រះគ្រីស្ទដែលទ្រង់យាងមក។ លោកម៉ូសេគ្រាន់តែជាហោរា។ រីឯលោកសាំយូអែលជាហោរាផង ជាសង្ឃផង។ ចំណែកព្រះអម្ចាស់យេស៊ូវទ្រង់ជាហោរា ជាសង្ឃ និងជាព្រះចមក្សត្រា។ ទ្រង់គឺជាឯកអង្គដែលបំពេញនាទីទាំងបីមុខនេះ គឺហោរា សង្ឃ ហើយនិងជាក្សត្រ។

យើងស្លេះការសិក្សាគម្ពីរ១សាំយូអែលត្រឹមណេះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"